

# អាងនៃទឹករស់


## អែលឌើរ ដាវីឌ អេ បែ៊តណា

### នៃកូរ៉ុមសាវកទាំងដប់ពីរនាក់


**ការប្រជុំស៊ីអ៊ីអេសសំរាប់មជ្ឈឹមវ័យ • ថ្ងៃទី 4 ខែកុម្ភៈ ឆ្នាំ 2007 • សាកលវិទ្យាល័យព្រីហ្គំយ៉ាំង**

ស៊ីស្ទើរបែ៊តណា និងខ្ញុំ មានអំណរគុណដែលបានជួបនឹងអ្នករាល់គ្នានៅរាត្រីនេះ។ នៅពេលយើងធ្វើដំណើរ ជាពិសេសយើងមានចិត្តអំណរដើម្បីប្រមូលផ្ដុំ និងរៀនជាមួយនឹងមនុស្សវ័យក្មេងស្មោះត្រង់ដូចជាអ្នករាល់គ្នា។ នៅរាត្រីនេះ ខ្ញុំអធិស្ឋានសុំជំនួយពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលយើងថ្វាយបង្គំជាមួយគ្នា ហើយស្វែងរកភាពសាមគ្គី ដើម្បីបានទទួលការបង្រៀនមកពីឋានលើ (សូមមើល គ និង ស 43:16)។

ខ្ញុំចង់ចាប់ផ្ដើមដោយការសួរនូវសំណួរសាមញ្ញមួយ។ តើសារធាតុ ឬទំនិញអ្វីដែលមានតម្លៃថ្លៃជាងគេបំផុត នៅក្នុងពិភពលោកនេះ? តំបូងប្រហែលជាយើងគិតថា មាស ប្រេង ឬពេជ្រ មានតម្លៃថ្លៃជាងគេបំផុត។ ប៉ុន្តែអ្វីដែល លើសពីធាតុរ៉ែ លោហៈធាតុ ត្បូង និងគ្រឿងដាក់រំលាយនានា ដែលមានតម្លៃបំផុតនោះគឺ ទឹក។

ប្រភពនៃជីវិតចេញមកពីទឹក។ ជីវិតត្រូវបានទ្រទ្រង់ដោយទឹក។ ទឹកតំរូវឱ្យមានជាមធ្យម ដើម្បីធ្វើមុខងារ ផ្សេងៗទៀតដែលទាក់ទងជាមួយនឹងទំរង់នានានៃជីវិត។ រូបរាងកាយរបស់យើង មានទឹកប្រហែលជាពីរភាគបី។ ខណៈ ដែលមនុស្សម្នាក់អាចរស់ជាច្រើនថ្ងៃ ឬដល់រាប់អាទិត្យបានដោយគ្មានអាហារ តែជាធម្មតាបុគ្គលម្នាក់នឹងស្លាប់នៅក្នុងរវាង ពីរបីថ្ងៃប៉ុណ្ណោះបើគ្មានទឹក។ ប្រជាជនភាគច្រើននៃពិភពលោក គឺបានតាំងនៅជិតនឹងប្រភពនៃទឹកបរិសុទ្ធ។ និយាយដោយសាមញ្ញថា ជីវិតមិនអាចរស់នៅដោយគ្មានការផ្គត់ផ្គង់ទឹកស្អាតឱ្យមានគ្រប់គ្រាន់នោះទេ។

## ទឹករស់

ដោយបានផ្ដល់តួនាទីដ៏សំខាន់របស់ទឹក នៅក្នុងការគាំទ្រដល់ទំរង់ជីវិតទាំងអស់ បន្ទូលរបស់ព្រះអង្គសង្គ្រោះ បានប្រើថា “ទឹករស់” គឺជាសេចក្ដីសំខាន់ដ៏ទេវភាព។ ដូចដែលបានពិពណ៌នានៅក្នុងយ៉ូហានជំពូកទីបួន ព្រះយេស៊ូវ និងសាវករបស់ទ្រង់ បានដើរឆ្លងកាត់ស្រុកសាម៉ារី ពេលធ្វើដំណើរពីស្រុកយូដា ទៅស្រុកកាលីឡេ។ នៅក្នុងទីក្រុងស៊ូខារ ពួកសាវក និងទ្រង់បានឈប់នៅកន្លែងអណ្ដូងរបស់យ៉ាកុប។

“មានស្ត្រីសាសន៍សាម៉ារីម្នាក់មកដងទឹក ហើយព្រះយេស៊ូវមានបន្ទូលទៅនាងថា សូមឱ្យខ្ញុំផឹកផង។

“(ព្រោះពួកសិស្សរបស់ទ្រង់បានទៅផ្សារអស់ ដើម្បីនឹងរកទិញស្បៀងអាហារ) ។

“ស្ត្រីសាសន៍សាម៉ារីនោះក៏ទូលថា លោកជាសាសន៍យូដា ម្ដេចឡើយក៏លោកសូមទឹកខ្ញុំពិសា ដែលខ្ញុំជាស្ត្រីសាសន៍សាម៉ារីដូច្នេះ? ត្បិតសាសន៍យូដាមិនដែលប្រកបនឹងសាសន៍សាម៉ារីទេ។

“ព្រះយេស៊ូវមានបន្ទូលឆ្លើយថា បើសិនជានាងបានស្គាល់អំណោយទាននៃព្រះ នឹងអ្នកដែលនិយាយនឹងនាងថា សូមឱ្យខ្ញុំផឹកផង នោះនាងនឹងបានសូមពីអ្នកនោះវិញ រួចអ្នកនោះនឹងឱ្យទឹករស់ដល់នាង។

“ស្ត្រីនោះក៏ទូលទ្រង់ថា លោកម្ចាស់ លោកគ្មានអ្វីនឹងដងទេ ហើយអណ្ដូងក៏ជ្រៅផង ដូច្នេះលោកបានទឹករស់នោះពីណាមក?...

“ព្រះយេស៊ូវមានបន្ទូលឆ្លើយថា អស់អ្នកណាដែលផឹកទឹកនេះ នឹងត្រូវស្រេកទៀតៈ

“តែអ្នកណាដែលផឹកទឹកខ្ញុំឱ្យ នោះនឹងមិនស្រេកទៀតឡើយ ទឹកដែលខ្ញុំឱ្យនឹងត្រឡប់ជារន្ធទឹកនៅក្នុងអ្នកនោះ ដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច” (យ៉ូហាន 4:7–11, 13–14)។

ទឹករស់ ដែលនៅក្នុងរឿងនេះសំដៅទៅលើនោះ គឺជាតំណាងឱ្យព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់។ ហើយដូចដែលថាទឹក មានសារៈសំខាន់ដើម្បីទ្រទ្រង់ជីវិតខាងរាងកាយ ដូច្នេះព្រះអង្គសង្គ្រោះ និងគោលលទ្ធិ គោលការណ៍ និងពិធីការទាំងឡាយរបស់ទ្រង់ មានសារៈសំខាន់សំរាប់ជីវិតដ៏នៅអស់កល្បជានិច្ច។ អ្នក និងខ្ញុំ ត្រូវការទឹករស់របស់ទ្រង់ប្រចាំថ្ងៃ ហើយត្រូវការនៅក្នុងការផ្គត់ផ្គង់យ៉ាងបរិបូរណ៍ចំពោះការរីកចំរើន និងការអភិវឌ្ឍន៍ខាងវិញ្ញាណជាដរាប។

## ព្រះគម្ពីរ គឺជាអាងនៃទឹករស់មួយ

ព្រះគម្ពីរមានបន្ទូលរបស់ព្រះគ្រីស្ទ ហើយគឺជាអាងនៃទឹករស់ ដែលយើងអាចប្រើដោយងាយស្រួល ហើយយើងអាចផឹកបានយូរអង្វែង។ អ្នក ហើយនឹងខ្ញុំត្រូវតែមើលទៅឯព្រះគ្រីស្ទ និងមករកព្រះគ្រីស្ទ ដែលជា “ប្រភពនៃទឹករស់” (នីហ្វៃទី 1 11:25 ប្រៀបធៀបនឹងអេធើរ 8:26, 12:28) ដោយការអាន (សូមមើល ម៉ូសាយ 1:5) ការសិក្សា (សូមមើល គ និង ស 26:1) ការស្ទង់មើល (សូមមើលយ៉ូហាន 5:39, អាលម៉ា 17:2) ការទទួលទាន (សូមមើល នីហ្វៃទី 2 32:3) ព្រះបន្ទូលនៃព្រះគ្រីស្ទ ដែលមាននៅក្នុងព្រះគម្ពីរបរិសុទ្ធទាំងឡាយ។ ដោយការធ្វើដូច្នេះ យើងអាចទទួលទាំងការការពារ និងការដឹកនាំខាងវិញ្ញាណ អំឡុងពេលធ្វើដំណើរនៅក្នុងជីវិតរមែងស្លាប់របស់យើង។

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ មានកិច្ចការពិសិដ្ឋមួយដើម្បីការពារនូវវិវរណៈដែលបានកំណត់ទុកឱ្យបានបរិសុទ្ធ និងសុវត្ថិភាព (សូមមើល គ និង ស 42:56)— អាងនៃទឹករស់ដ៏មានតម្លៃនេះ។ កិច្ចការដ៏ធំមួយ ត្រូវបានសំរេចដោយសាសនាចក្រនៅក្នុង សតវត្សន៍ 1970 និង 1980 ហើយលទ្ធផលជា



© 2007 by Intellectual Reserve, Inc។ រក្សាសិទ្ធគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/06។ អនុមតិការបកប្រែៈ 6/06 ។ ការបកប្រែនៃ “A Reservoir of Living Water.” 02153 258

ការបោះពុម្ពនៃព្រះគម្ពីរ ដែលយើងចូលចិត្តនៅសព្វថ្ងៃនេះជាមួយនឹងលេខយោង សេចក្តីយោង និងជំនួយការសិក្សា ផែនទី និងព័ត៌មានមកបន្ថែមទៀត។

នៅពេលព្រះគម្ពីរដែលបានធ្វើបច្ចុប្បន្នភាព ត្រូវបានណែនាំនៅលើកដំបូងដល់សមាជិកសាសនាចក្រ នៅក្នុងដើម សតវត្សន៍ 1980 អែលឌើរ ប៊យ឵ឃេ ផាកកឺ បានព្យាករថាៈ

“អស់ជាច្រើនឆ្នាំកន្លងផុតទៅ បទគម្ពីរទាំងនេះ នឹងផលិតជាជំនាន់តៗគ្នានៃពួកគ្រីស្ទានស្មោះត្រង់ ដែលស្គាល់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងត្រូវបង្អោនទៅគោរពតាមព្រះទ័យរបស់ទ្រង់។

“ជំនាន់ចាស់ៗ ត្រូវបានធំឡើងដោយគ្មានបទគម្ពីរ ប៉ុន្តែមានជំនាន់ផ្សេងទៀតកំពុងរីកចំរើនឡើង” (“in Conference Report ខែតុលា ឆ្នាំ 1982, 75” ឬ *Ensign,* ខែវិច្ឆិកា ឆ្នាំ1982, 53)។

ម្ភៃប្អូនឆ្នាំបានកន្លងផុតទៅ ចាប់តាំងពីអែលឌើរផាកកឺមានប្រសាសន៍ពាក្យទាំងនោះ។ ហើយជំនាន់ដែលលោកបានសំដៅមកលើនោះ គឺបានអង្គុយនៅរាត្រីនេះ នៅក្នុងអគារសាសនាចក្រ នៅទូទាំងផែនដី! លោកបាននិយាយអំពីអ្នករាល់គ្នា ហើយលោកនិយាយអំពីខ្ញុំ។ អ្នករាល់គ្នាក្នុងចំនួនដ៏ច្រើននេះបានស្គាល់ ព្រះគម្ពីរតែនៅពេលយើងមានវានៅសព្វថ្ងៃនេះប៉ុណ្ណោះ។ សូមចងចាំក្នុងចិត្ត នៅពេលខ្ញុំបន្តដកស្រង់ប្រសាសន៍របស់អែលឌើរ ផាកកឺៈ

“វិវរណៈទាំងឡាយនឹងបើកសម្តែងដល់ពួកគេ ដែលគ្មានអ្នកណាផ្សេងទៀត នៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោក។ ឥឡូវនៅក្នុងដៃរបស់ពួកគេ មានទូវបន្ទះឈើរបស់យ៉ូសែប និងរបស់យូដា។ ពួកគេនឹងអភិវឌ្ឍការសិក្សាដំណឹងល្អលើសពីអ្វីដែលជីដូនជីតារបស់ពួកគេ អាចសំរេចបាន។ ពួកគេនឹងមានទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយមានសមត្ថភាពគ្រប់គ្រាន់ដើម្បីប្រកាសអំពីទ្រង់ និងការពារទ្រង់” (“in Conference Report ខែតុលា ឆ្នាំ 1982, 75” ឬ *Ensign,* ខែវិច្ឆិកា ឆ្នាំ 1982, 53)។

យើងមិនគ្រាន់តែត្រូវបានប្រទានឱ្យមានព្រះគម្ពីរទាំងនេះជាស្រេចសំរាប់យើងនៅសព្វថ្ងៃនេះប៉ុណ្ណោះទេ ប៉ុន្តែយើងក៏មានទូវភារៈកិច្ចដើម្បីប្រើវាឱ្យខ្ជាប់ខ្ជួន និងដោយមានប្រសិទ្ធភាពផងដែរ ហើយផឹកចូលទៅក្នុងខ្លួនទូវទឹកដែលចេញ មកពីអាងនៃប្រភពទឹករស់។ ខ្ញុំជឿថាជំនាន់នៃយុវវ័យនេះ មានការសិក្សាយ៉ាងស្និតស្នាញនៅក្នុងព្រះគម្ពីរកាន់តែច្រើន កាន់តែស្គាល់យ៉ាងច្បាស់ទូវពាក្យរបស់ព្យាការីទាំងឡាយ ហើយកាន់តែបន្ទាបខ្លួនបែរទៅរកវិវរណៈជាចំលើយខ្លួន ជាជាងជំនាន់មុនៗ។ ប៉ុន្តែយើងនៅតែមានចំងាយយ៉ាងឆ្ងាយ ដើម្បីធ្វើដំណើរតាមផ្លូវតូច និងចង្អៀត—ដែលមានអ្វីៗកាន់តែច្រើនដើម្បីរៀន អនុវត្ត និងមានបទពិសោធន៍ថែមទៀត។

## ការទទួលទឹករស់ចេញមកពីអាងទឹកព្រះគម្ពីរ

ឥឡូវនេះ ខ្ញុំចង់រំលឹកជាមួយអ្នករាល់គ្នាទូវវិធីជាមូលដ្ឋានបី ឬវិធីសាស្ត្រនៃការទទួលទឹករស់ចេញមកពីអាងទឹកព្រះគម្ពីរៈ (1) *ការអាន* ព្រះគម្ពីរចាប់ពីដើមរហូតដល់ចប់ (2) *ការសិក្សា* ព្រះគម្ពីរតាមប្រធានបទ និង (3) *ការស្ទង់មើល* បទគម្ពីររកមើលពីទំនាក់ទំនង គំរូ និងបាវចនារបស់វា។ មធ្យោបាយ និមួយៗទាំងនេះ អាចជួយបំបាត់ភាពស្រេកឃ្លានខាងវិញ្ញាណរបស់យើង បើយើងអញ្ជើញភាពជាដៃគូ និងជំនួយរបស់ ព្រះវិញ្ញាណបរិសុទ្ធ នៅពេលយើងអាន សិក្សា និងស្ទង់មើលបទគម្ពីរ។

*ការអាន* សៀវភៅគម្ពីរតាំងពីដើមរហូតដល់ចប់ វាចាប់ផ្តើមឱ្យមានលំហូរនៃទឹករស់ចូលមកក្នុងជីវិតរស់នៅ របស់យើង ដោយការនាំឱ្យយើងស្គាល់នូវរឿងសំខាន់ៗស្គាល់គោលលទ្ធិដំណឹងល្អ និងគោលការណ៍ដែលគ្មានទីបញ្ចប់។ មធ្យោបាយនេះក៏ជួយយើងឱ្យរៀនអំពីចរិកលក្ខណៈចំបងនៅក្នុងបទគម្ពីរ លំដាប់លំដោយ ពេលវេលា បរិបទនៃព្រឹត្តការណ៍ និងការបង្រៀន។ ការអានកំណត់បទគម្ពីរតាមរបៀបនេះសម្តែងឱ្យយើងឃើញពីកណ្តាលនៃ ព្រះគម្ពីរទាំងអស់។ នេះគឺជាមធ្យោបាយគ្រឹះ និងដំបូងបំផុតនៃការទទួលទឹករស់។

*ការសិក្សា* តាមប្រធានបទ ជាធម្មតា ធ្វើតាម វិកលូតលាស់ ហើយសង់លើការអានបទគម្ពីររបស់យើង ចាប់តាំងពីដើមរហូតដល់ចប់។ ឧទាហរណ៍ នៅពេលយើងអានព្រះគម្ពីរមរមន យើងអាចស្គាល់ និងស្វែងរកចំលើយចំពោះសំណួរអំពីគោលលទ្ធិ និងសំណួរប្រាកដនិយមទាំងឡាយ ដូចខាងក្រោមនេះៈ

- តើសេចក្តីជំនឿលើព្រះអង្គសង្គ្រោះជាអ្វី?
- ហេតុអ្វីបានជាសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ គឺជាគោលការណ៍ដំបូងនៃព្រះសិក្ខាបទ?
- ហេតុអ្វី ហើយយ៉ាងដូចម្តេចបានជាសេចក្តីជំនឿលើព្រះប្រោសលោះនាំទៅរកការប្រែចិត្ត?
- តើដង្វាយធួនពង្រឹងដល់ខ្ញុំឱ្យធ្វើកិច្ចការនៅក្នុងជីវិតរបស់ខ្ញុំប្រចាំថ្ងៃ ដែលខ្ញុំមិនអាចធ្វើបានដោយខ្លួនឯង ព្រោះតែសមត្ថភាពមានកំណត់របស់ខ្ញុំបានដោយរបៀបណា?

ការផ្តោតទៅលើសំណួរ និងការសិក្សាតាមប្រធានបទ ដោយប្រើការណែនាំនៅក្នុងព្រះគម្ពីរ នាំឱ្យយើងស្រាវជ្រាវ និងរុករកជំរៅបទគម្ពីរ ហើយទទួលបានចំណេះដឹងខាងវិញ្ញាណយ៉ាងច្រើន។ មធ្យោបាយនេះ បង្កើនអត្រាលំហូរ នៃទឹករស់ក្នុងជីវិតរបស់យើង។

ទាំងការអានពីដើមរហូតដល់ចប់ និងការសិក្សាតាមប្រធានបទ គឺជាតំរូវការដើម្បីចូលទៅវិធីសាស្ត្រមូលដ្ឋាន ទីបីនៃការទទួលទឹករស់ចេញមកពីអាងព្រះគម្ពីរ។ ដូច្នេះការអានសៀវភៅគម្ពីរតាំងពីដើមរហូតដល់ចប់ ផ្តល់នូវទស្សនៈចំបងនៃចំណេះដឹង ការសិក្សាតាមប្រធានបទ បង្កើនការចេះដឹងរបស់យើងឱ្យជ្រៅជ្រះ។ *ការស្ទង់មើល* នៅក្នុងវិវរណៈរកមើលពីទំនាក់ទំនង គំរូ និងបាវចនា គឺសង់នៅលើ និងបន្ថែមលើចំណេះដឹងខាងវិញ្ញាណរបស់យើង ដោយការបូកបញ្ចូល និងពង្រីកវិធីសាស្ត្រពីរដំបូងនោះ វាពង្រីកទស្សនវិស័យ និងការយល់ដឹងរបស់យើងអំពីផែនការ នៃសេចក្តីសង្គ្រោះ។ នៅក្នុងការវិនិច្ឆ័យរបស់ខ្ញុំ ខ្ញុំថាការស្ទង់មើលដោយឧស្សាហ៍ដើម្បីរកឱ្យឃើញពី ទំនាក់ទំនង គំរូ និងបាវចនានានា គឺជាផ្នែកដែលមានន័យថា “ទទួលទាន” នូវព្រះបន្ទូលនៃព្រះគ្រីស្ទ។ មធ្យោបាយនេះ អាចបើករបាំងនៃអាងព្រះគម្ពីរ បំភ្លឺ



© 2007 by Intellectual Reserve, Inc។ រក្សាសិទ្ធគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/06។ អនុមតិការបកប្រែៈ 6/06 ។ ការបកប្រែនៃ “A Reservoir of Living Water.” 02153 258

ការយល់ដឹងរបស់យើងតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ ហើយផលិតនូវអំណរគុណដ៏ខ្ពង់ខ្ពស់ចំពោះព្រះគម្ពីរបរិសុទ្ធ និងកំរិតនៃការតាំងចិត្តខាងវិញ្ញាណ ដែលមិនអាចទទួលបាន តាមរបៀបផ្សេងឡើយ។ ការស្ទង់មើលរបៀបនេះ អាចឱ្យយើងសង់គ្រឹះនៅលើសិលានៃព្រះដ៏ប្រោសលោះរបស់យើង ហើយទប់ទល់នឹងខ្យល់នៃអំពើទុច្ចរិតនៅក្នុងថ្ងៃចុងក្រោយនេះ។

ខ្ញុំចង់បញ្ជាក់អំពីចំនុចសំខាន់មួយ។ អ្នកប្រហែលជាស្មានពីដំបូងថា មនុស្សម្នាក់ត្រូវតែមានការអប់រំជាផ្លូវការធំទូលាយ ដើម្បីប្រើប្រាស់វិធីសាស្ត្រដែលខ្ញុំបានពិពណ៌នា។ ការស្មាននេះតាមពិតមិនត្រឹមត្រូវទេ។ អ្នកស្វែងរកសេចក្ដីពិតដ៏ស្មោះត្រង់គ្រប់រូប មិនថាមានប្រវត្តិការសិក្សាយ៉ាងណាទេ អាចប្រើមធ្យោបាយសាមញ្ញៗទាំងនេះដោយជោគជ័យ។ អ្នក និងខ្ញុំមិន ត្រូវការជំនួយការសិក្សាដែលពិបាកៗទេ ហើយក៏មិនគួរពឹងផ្អែកទាំងស្រុងលើចំណេះដឹងខាងវិញ្ញាណរបស់អ្នកដទៃដែរ។ យើងគ្រាន់តែត្រូវការមានចំណង់ដោយស្មោះមួយដើម្បីរៀន ភាពដៃគូរបស់ព្រះវិញ្ញាណបរិសុទ្ធ ព្រះគម្ពីរបរិសុទ្ធទាំងឡាយ ហើយនឹងគំនិតសកម្ម និងការចង់ដឹងចង់ឃើញប៉ុណ្ណោះ។

ព្យាការីយ៉ូសែប ស្ម៊ីធ បានបង្រៀនថា យើងគួរតែ “ស្ទង់មើលបទគម្ពីរ—ស្ទង់មើលវិវរណះទាំងឡាយ ដែលយើងបានបោះពុម្ព ហើយសួរដល់ព្រះវរបិតាសួគ៌របស់អ្នក នៅក្នុងព្រះនាមនៃព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ឱ្យបើកសម្ដែងសេចក្ដីពិតមកដល់អ្នក ហើយបើអ្នកធ្វើដូច្នោះដោយភ្នែកស្មោះស្ម័គ្រទាំងស្រុង ចំពោះសិរីល្អរបស់ព្រះអង្គដោយ គ្មានសង្ស័យអ្វីឡើយ នោះទ្រង់នឹងឆ្លើយដល់អ្នក ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ របស់ទ្រង់។ នោះអ្នកនឹងបានដឹងសំរាប់ខ្លួនអ្នក មិនមែនសំរាប់អ្នកដទៃទេ។ នោះអ្នកនឹងមិនពឹងផ្អែកទៅលើមនុស្ស ចំពោះចំណេះដឹងអំពីព្រះទេ” (*History of the Church* 1:282)។

បើអ្នក និងខ្ញុំ សុំ ស្វែងរក និងគោះ (សូមមើល ម៉ាថាយ 7:7) រក្សាខ្លួនយើងឱ្យសក្ដិសមជានិច្ច ដើម្បីរៀនមកពីព្រះវិញ្ញាណ នោះទ្វារនៃអាងព្រះគម្ពីរនឹងបើកឱ្យយើង ហើយទឹករស់នឹងហូរចូលក្នុងខ្លួនយើង។ ខ្ញុំសូមធ្វើជាសាក្សី ធ្វើទីបន្ទាល់ និងសន្យាថា ការណ៍នេះគឺជាការពិត។

ខ្ញុំសូមពន្យល់ដោយសង្ខេប និងផ្ដល់ឧទាហរណ៍អំពីអ្វីដែលខ្ញុំចង់មានន័យអំពីការទំនាក់ទំនង គំរូ និងបាវចនា។

## ការទំនាក់ទំនង

ទំនាក់ទំនងគឺជាការទាក់ទង ឬការភ្ជាប់រវាងគំនិត មនុស្ស វត្ថុ ឬព្រឹត្តិការណ៍ ហើយបទគម្ពីរមានពេញទៅ ដោយទំនាក់ទំនង។ ចូរពិចារណាអំពីការទាក់ទងរវាងព្រះវរបិតាដ៏អស់កល្បជានិច្ច និងបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ (សូមមើល ម៉ូសាយ 15:1-9) រវាងសេចក្ដីមេត្តាករុណា និងព្រះគុណ (សូមមើល នីហ្វៃទី 2 9:8) រវាងដៃស្អាត និងចិត្តបរិសុទ្ធ (សូមមើល ទំនុកដំកើង 24:4) រវាងចិត្តសង្រេង និងវិញ្ញាណទន់ទាប (សូមមើល នីហ្វៃទី 3 9:20) រវាងស្រូវសាលី និងស្រងែ (សូមមើល គ និង ស 101:65) រវាងបញ្ញា និងចំណេះវិជ្ជា (សូមមើល គ និង ស 130:18-19) រវាងយុត្តិធម៌ និងការញែកចេញជាបរិសុទ្ធ (សូមមើល គ និង ស 20:30-31) រវាងចៀម និងពពែ (សូមមើល ម៉ាថាយ 25:32-33) រវាងអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ច (សូមមើល ម៉ូសេ 1:39) និងអ្វីផ្សេងទៀតរាប់មិនអស់។ ចូរស្គាល់ រៀន និងគិតពិចារណាអំពីការទំនាក់ទំនងនេះ—នូវភាពដូចគ្នា និងភាពខុសគ្នាប្រកបដោយការអធិស្ឋាន ឧទាហរណ៍—វាជាប្រភពសំខាន់នៃទឹករស់ ហើយនាំទៅរកការយល់ដឹង ជ្រៅជ្រះដ៏បំផុសគំនិត និងសន្សំទុកនូវចំណេះដឹងដែលលាក់កំបាំង។

នៅពេលខ្ញុំអានបទដ្ឋានព្រះគម្ពីរនិមួយៗចាប់ពីដើមដល់ចប់ ហើយសិក្សាអំពីប្រធានបទផ្សេងៗគ្នា ខ្ញុំបានកត់សំគាល់ឃើញថាពាក្យ *ការយល់ដឹង* ត្រូវបានពិពណ៌នាជាទូទៅនៅក្នុងទំនាក់ទំនងទៅនឹងចិត្ត។ ខគម្ពីរចំនួនពីរ នៅក្នុងព្រះគម្ពីរមរមនបង្ហាញអំពីការទំនាក់ទំនងនេះ។

“អ្នកពុំបាន*តាំងចិត្ត* រៀន*ឱ្យយល់* ហេតុនេះ អ្នកពុំមានប្រាជ្ញាទេ ហេតុដូច្នេះ តើអ្នកបង្រៀនអ្វីដល់ប្រជាជននេះ? ” (ម៉ូសាយ 12: 27 បន្ថែមអក្សរទ្រេត)។

“ហើយហ្វូងមនុស្សបានឮ ហើយបានធ្វើបន្ទាល់ ហើយ*ចិត្ត* គេបើកចំហបណ្ដាលឱ្យគេ*យល់* នូវពាក្យដែលទ្រង់ អធិស្ឋាន” (នីហ្វៃទី 3 19: 33 បន្ថែមអក្សរទ្រេត)។

ខ្ញុំរកឃើញវាគួរឱ្យចាប់អារម្មណ៍បំផុតនៅក្នុងខទាំងពីរនេះ និងខដទៃទៀតថា ការយល់ ត្រូវបានភ្ជាប់ជាសំខាន់ទៅនឹងចិត្ត។ ចូរកត់ចំណាំថា យើងមិនបានទូន្មានឱ្យច្បាស់ ដើម្បីអនុវត្តគំនិតរបស់យើង ទៅជាការយល់ទេ។ ជាក់ស្ដែង យើងត្រូវតែប្រើគំនិតយើង និងសមត្ថភាពសមហេតុផលយើងដើម្បីទទួល និងវិភាគលើព័ត៌មាន និងដើម្បីឈោងទៅដល់សេចក្ដីសន្និដ្ឋានសមរម្យ រួចហើយវិនិច្ឆ័យ។ ប៉ុន្តែប្រហែលជាបទគម្ពីរ កំពុងតែឱ្យយោបល់យើងថា ហេតុផល និង “ដៃនៃមនុស្ស” (គ និង ស 1:19) គឺមិនគ្រប់គ្រាន់ដើម្បីបង្កើត ជាការយល់ដឹងពិតទេ។ ហេតុដូច្នេះ ការយល់ដូចដែលប្រើនៅក្នុងបទគម្ពីរ មិនសំដៅត្រឹមតែ ឬជាបឋមចំពោះបញ្ញា ឬ គំនិតដឹងស្គាល់នោះឡើយ។ ផងដែរ ការយល់ កើតឡើងនៅពេលដែលអ្វីដែលយើងដឹង នៅក្នុងគំនិត ត្រូវបានបញ្ជាក់ជាការពិតនៅក្នុងដួងចិត្តរបស់យើង តាមរយៈព្រះវិញ្ញាណបរិសុទ្ធធ្វើជាសាក្សី។

ដែលសាមញ្ញបំផុតនោះ អំណោយទានខាងវិញ្ញាណនៃវិវរណះ ធ្វើការជាគំនិត និងអារម្មណ៍ដាក់នៅក្នុង គំនិតរបស់យើង និងដួងចិត្តដោយព្រះវិញ្ញាណបរិសុទ្ធ (សូមមើល គ និង ស 8:2–3, 100:5–8)។ ហើយនៅពេល ដែលទីបន្ទាល់ និងការផ្លាស់ប្រែចិត្តជឿប្ដូរពីគំនិតរបស់យើងចូលទៅក្នុងដួងចិត្តរបស់យើង យើងនឹងមិនគ្រាន់តែមាន ព័ត៌មាន ឬចំណេះដឹងទេ—ប៉ុន្តែយើងចាប់ផ្ដើមយល់ ហើយស្វែងរកបន្ទាប់ពីការផ្លាស់ប្ដូរដ៏ធំនៅក្នុងដួងចិត្ត។ ខណៈនោះ ការយល់ គឺជាលទ្ធផលនៃវិវរណះ វាជាអំណោយទានខាងវិញ្ញាណ វាជាតំរូវការដំបូងទៅរកការផ្លាស់ប្រែចិត្តជឿ ហើយញុះញង់យើងឱ្យរស់នៅកាន់តែខ្ជាប់ខ្ជួនទៅតាមគោលការណ៍ទាំងឡាយដែលយើងកំពុងតែរៀន។



© 2007 by Intellectual Reserve, Inc។ រក្សាសិទ្ធគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/06។ អនុមតិការបកប្រែៈ 6/06 ។ ការបកប្រែនៃ “A Reservoir of Living Water.” 02153 258

ការណ៍នេះបង្ហាញឱ្យឃើញច្បាស់អំពីទំនាក់ទំនងរវាងដួងចិត្ត និងការយល់ ថាមធ្យោបាយរបស់ខ្ញុំ បានមានឥទ្ធិពលដ៏ធំចំពោះការរៀន និងការសិក្សាដំណឹងល្អ ដែលបានមានឥទ្ធិពលវិជ្ជមានតាមរបៀបដែលស៊ូស្ហ៊ី បែតណា និងខ្ញុំបង្រៀនកូនចៅរបស់យើង ហើយមានឥទ្ធិពលលើការបំរើបព្វជិតភាពរបស់ខ្ញុំ។

## គំរូ

គំរូ គឺជាគម្រោង ម៉ូត ឬបទដ្ឋានដែលអាចប្រើជាការណែនាំសំរាប់ធ្វើអ្វីដដែលៗ ឬបង្កើតអ្វីមួយ។ ហើយរូបភាព ទាំងឡាយមានពេញទៅដោយគំរូខាងវិញ្ញាណ។ ជាធម្មតា គំរូព្រះគម្ពីរមួយ គឺមានភាពធំទូលាយ និងពេញលេញជាងការទំនាក់ទំនង។ នៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា យើងរកឃើញគំរូសំរាប់ផ្សព្វផ្សាយដំណឹងល្អ (សូមមើល គ និង ស 50:13–29) ដើម្បីចៀសវាងការបញ្ឆោត (សូមមើល គ និង ស 52:14; 18–19) ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ (សូមមើល គ និង ស 115:14–16) សំរាប់ស្ថាបនាទីក្រុង (សូមមើល គ និង ស 94) សំរាប់បង្កើតក្រុមបព្វជិតភាព (សូមមើល គ និង ស 107:85–100) និងក្រុមប្រឹក្សាជាន់ខ្ពស់ (សូមមើល គ និង ស 102:12) និងសំរាប់គោលបំណងផ្សេងៗទៀតជាច្រើន។ ការស្គាល់ និងការសិក្សាពីគំរូព្រះគម្ពីរ គឺជាប្រភពសំខាន់មួយទៀតនៃទឹករស់ ហើយជួយយើងឱ្យស្គាល់ និងកាន់តែស្គាល់ប្រាជ្ញា និងព្រះហឫទ័យនៃព្រះអម្ចាស់ (សូមមើល គ និង ស 95:13)។

នៅពេលដែលខ្ញុំបានអានគោលលទ្ធិ និងសេចក្តីសញ្ញាតាំងពីដើមដល់ចប់ និងសិក្សាតាមប្រធានបទ ខ្ញុំចាប់អារម្មណ៍ទឹងគំរូមួយដែលជាភស្តុតាងនៅក្នុងការឆ្លើយតបជាច្រើនរបស់ព្រះអម្ចាស់ ចំពោះសំណួរទាំងឡាយរបស់អ្នកផ្សព្វផ្សាយសាសនា។ នៅខណៈខ្លះក្នុងឆ្នាំ 1831 ក្រុមអែលឌើរផ្សេងៗ ដែលបានហៅឱ្យផ្សព្វផ្សាយដំណឹងល្អ បានមានបំណងចង់ដឹងថាគេគួរធ្វើអ្វី និងទៅផ្លូវណា ហើយគេគួរធ្វើដំណើរយ៉ាងម៉េច។ នៅក្នុងវិវរណៈដែលផ្តល់ឱ្យតាមរយៈព្យាការីយ៉ូសែប ស្ម៊ិធ ព្រះអម្ចាស់បានទូន្មានដល់បងប្អូនប្រុសទាំងនេះ រឿងៗខ្លួនថា ពួកគេអាចធ្វើដំណើរតាមផ្លូវទឹក ឬផ្លូវដី (សូមមើល គ និង ស 61:22) ថាពួកគេអាចធ្វើ ឬទិញរថយន្ត ដែលចាំបាច់ (សូមមើល គ និងស 60:5) ថាពួកគេអាចធ្វើដំណើរទាំងអស់គ្នា ឬទៅពីរៗនាក់ (សូមមើល គ និង ស 62:5) ហើយថាពួកគេអាចធ្វើដំណើរតាមទិសដៅផ្សេងៗមួយចំនួន (សូមមើល គ និង ស 80:3)។ វិវរណៈបានបង្រៀនជាពិសេសឱ្យបងប្អូនប្រុសធ្វើការសំរេចចិត្តទាំងនេះ "ដូចដែលឃើញថាល្អដល់អ្នក" (សូមមើល គ និងស 60:5, 62:5) ឬ "ដូចដែលបានធ្វើឱ្យពួកគេដឹង តាមការវិនិច្ឆ័យរបស់ពួកគេ" (គ និង ស 61:22)។ ហើយនៅក្នុងឧទាហរណ៍នីមួយៗទាំងនេះ ព្រះអង្គសង្គ្រោះបានប្រកាសថា "វាមិនសំខាន់ដល់យើងឡើយ" (គ និងស 60:5, 61:22, 62:5, 63:40 និងសូមមើល 80:3 ផងដែរ)។

បន្ទូលរបស់ព្រះអម្ចាស់ថារឿងទាំងនេះ " វាមិនសំខាន់ដល់យើងឡើយ" ដែលតំបូងមើលទៅអាចភ្ញាក់ផ្អើល។ ច្បាស់ណាស់ ព្រះអង្គសង្គ្រោះមិនបានមានបន្ទូលទៅកាន់អ្នកផ្សព្វផ្សាយសាសនាទាំងនេះថា ទ្រង់មិនយកព្រះទ័យនឹង ពួកគេចំពោះអ្វីដែលពួកគេកំពុងធ្វើនោះទេ។ ផងដែរ ទ្រង់បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការដាក់រឿងទីមួយឱ្យទៅ តំបូងគេ ហើយផ្តោតទៅលើរឿងត្រឹមត្រូវ—ដែលនៅក្នុងឧទាហរណ៍ទាំងនេះ ត្រូវទៅតំបន់ដែលចាត់ឱ្យទៅធ្វើការ ហើយចាប់ផ្តើមធ្វើកិច្ចការនោះ។ ពួកគេត្រូវអនុវត្តសេចក្តីជំនឿ ប្រើការវិនិច្ឆ័យឱ្យល្អ ធ្វើកិច្ចការទៅតាមការដឹកនាំរបស់ព្រះវិញ្ញាណ ហើយកំណត់ផ្លូវដែលល្អបំផុត ដើម្បីធ្វើដំណើរទៅកាន់កន្លែងដែលពួកគេ ចាត់ឱ្យទៅ។ រឿងចាំបាច់គឺជាកិច្ចការដែលពួកគេត្រូវបានហៅឱ្យទៅធ្វើ ការដែលត្រូវទៅដោយរបៀបណា គឺជារឿងសំខាន់ដែរ ប៉ុន្តែមិនចាំបាច់ទេ។

នេះគឺជាគំរូដ៏អស្ចារ្យសំរាប់អ្នក និងខ្ញុំដើម្បីអនុវត្តនៅក្នុងជីវិតរស់នៅរបស់យើង។ ព្រះយេស៊ូវគ្រីស្ទ ស្គាល់ ហើយស្រឡាញ់យើងម្នាក់ៗ។ ទ្រង់បារម្ភអំពីការអភិវឌ្ឍន៍ និងការរីកចំរើនខាងវិញ្ញាណរបស់យើង ហើយទ្រង់លើកទឹកចិត្តយើងឱ្យរីកចំរើនតាមរយៈការអនុវត្តការវិនិច្ឆ័យដោយវៃឆ្លាត សុចរិត និងដោយបំផុសគំនិត។ ព្រះប្រោសលោះនឹងមិនបោះបង់ឱ្យយើងទៅតែម្នាក់ឯងទេ។ យើងគួរតែអធិស្ឋានជានិច្ចសុំការដឹកនាំ និងការណែនាំ។ យើងគួរតែស្វែងរកភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធឱ្យបានខ្ជាប់ខ្ជួនជានិច្ច។ ប៉ុន្តែយើងមិនគួរភ័យខ្លាច ឬបាក់ទឹកចិត្តទេ បើចំលើយចំពោះការទូលអង្វររបស់យើងសំរាប់ការដឹកនាំ ឬជំនួយមិនចាំបាច់ឆ្លើយតបឱ្យបានឆាប់រហ័សនោះ។ ចំលើយដូច្នេះកម្រមានមកទាំងអស់ក្នុងពេលតែមួយណាស់។ ការរីកចំរើនរបស់យើងនឹងថយចុះ ហើយការវិនិច្ឆ័យ របស់យើងនឹងទន់ខ្សោយ បើគ្រប់ចំលើយត្រូវបានឆ្លើយមកដល់យើងភ្លាមៗ ហើយគ្មានគំរូឱ្យបង់ថ្លៃនៃសេចក្តីជំនឿ កិច្ចការ ការសិក្សា និងភាពបិតថេរនោះ។

គំរូដែលខ្ញុំកំពុងពិពណ៌នា ត្រូវបានបង្ហាញយ៉ាងខ្លី និងច្បាស់លាស់នៅក្នុងការបង្រៀនទៅកាន់អ្នកផ្សព្វផ្សាយ សាសនាពីមុនៗដូចខាងក្រោម៖

"យើងជាព្រះអម្ចាស់យល់ព្រម បើសិនជាមាននរណាមួយនៅក្នុងចំណោមអ្នក មានប្រាថ្នាចង់ជិះលើសេះ ឬលើលា ឬលើរទេះទាំងឡាយ អ្នកនោះនឹងបានទទួលព្រះពរនេះហើយ បើសិនជាអ្នកនោះទទួលពរពីព្រះហស្តនៃព្រះអម្ចាស់ ដោយមាន*ចិត្តអរគុណក្នុងគ្រប់ការណ៍ទាំងអស់*។

"ការណ៍ទាំងនេះនៅជាមួយអ្នក ដើម្បីប្រព្រឹត្ត*តាមការវិនិច្ឆ័យ និងតាមការដឹកនាំពីព្រះវិញ្ញាណ*។

"មើលចុះ នគរជារបស់ផងអ្នកហើយ។ ហើយមើលចុះ និងមើលន៏ *យើងគង់នៅជាមួយពួកស្មោះត្រង់ជានិច្ច*។ គឺដូច្នោះមែន។ អាម៉ែន " (សូមមើល គ និង ស 62:7-9 បន្ថែមអក្សរទ្រេត)។

រឿងសំខាន់បំផុតនៅក្នុងខគម្ពីរនេះ គឺមិនមែនជាសេះ លា ឬរទេះទេ តែជាការដឹងគុណ ការវិនិច្ឆ័យ និងសេចក្តីស្មោះត្រង់។ សូមកត់ចំណាំនូវធាតុសំខាន់នៅក្នុងគំរូនេះ៖ (1) ចិត្តអរគុណក្នុងគ្រប់ការណ៍ទាំងអស់ (2) ធ្វើទង្វើតាមការវិនិច្ឆ័យ និង



© 2007 by Intellectual Reserve, Inc។ រក្សាសិទ្ធគ្រប់យ៉ាង។ បោះពុម្ភនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/06។ អនុមតិការបកប្រែៈ 6/06 ។ ការបកប្រែនៃ "A Reservoir of Living Water." 02153 258

តាមការដឹកនាំពីព្រះវិញ្ញាណ និង (3) ព្រះអង្គសង្គ្រោះគង់នៅជាមួយពួកស្មោះត្រង់ជានិច្ច។ តើយើងអាចចាប់ផ្ដើមទទួលអារម្មណ៍នៃការដឹកនាំ និងការអះអាង ការចាប់ផ្ដើមជាថ្មី និងកម្លាំង ដែលអាចមានមកតាមការធ្វើតាមគំរូនេះដើម្បីបំផុសគំនិត និងវិនិច្ឆ័យសុចរិតឬទេ? ពិតណាស់ គំរូព្រះគម្ពីរ គឺជាប្រភពដ៏មានតម្លៃនៃទឹករស់។

ការវិនិច្ឆ័យដែលយើងត្រូវការធ្វើបំផុត គឺកម្រមានរវាងល្អ និងអាក្រក់ ឬរវាងការទាក់ទាញ និងមិនទាក់ទាញណាស់។ ជាធម្មតា ការសំរេចចិត្តជ្រើសរើសដែលពិបាកជាងគេបំផុតរបស់យើង គឺរវាងល្អ និងល្អ។ នៅក្នុងរឿងព្រះគម្ពីរ សេះ លា និងរទេះនេះអាចជាជំរើសដែលមានប្រសិទ្ធភាពស្មើគ្នាចំពោះអ្នកផ្សព្វផ្សាយសាសនាធ្វើដំណើរ។ តាមរបៀបស្រដៀងគ្នានេះ អ្នក និងខ្ញុំ អាចស្គាល់នៅតាមពេលផ្សេងៗ នៅក្នុងជីវិតរបស់យើង ច្រើនជាងឱកាសមួយដែលអាចទទួលយកបាន ឬជំរើសមួយដែលយើងអាចជ្រើសរើសដើម្បីប្រដេញតាម។ យើងគួរតែចងចាំគំរូចេញមកពីបទគម្ពីរនេះ នៅពេលយើងទៅដល់ការធ្វើការសំរេចចិត្តសំខាន់ៗ។ បើយើងដាក់រឿងចាំបាច់មុននៅក្នុងជីវិតរបស់យើង—រឿងដូចជាភាពជាសិស្សនៃព្រះដែលមានការលះបង់ ការគោរពសេចក្ដីសញ្ញា និងរក្សាបទបញ្ញត្តិទាំងឡាយ—នោះយើងនឹងទទួលពរជ័យជាមួយនឹងការបំផុសគំនិត និងការវិនិច្ឆ័យម៉ឺងម៉ាត់ នៅពេលយើងឆ្ពោះទៅនៅលើផ្លូវដែលនាំយើងត្រឡប់ទៅផ្ទះនៅឋានសួគ៌របស់យើង។ បើយើងដាក់រឿងចាំបាច់មុន យើង "មិនអាចធ្វើខុសឡើយ" (គ និង ស 80:3)។

## បាវចនា

បាវចនា គឺជាការសំខាន់ កើតផ្ទួនៗ ហើយមានគុណសម្បត្តិ ឬគំនិតឯកភាពគ្នា ដូចជាអំបោះត្បាញជាខោអាវ។ ជាទូទៅ បាវចនាព្រះគម្ពីរ មានភាពទូលំទូលាយ និងពេញលេញ ជាងគំរូ ឬការទំនាក់ទំនង។ ជាការពិតថា បាវចនា ផ្ដល់ជាប្រវត្តិ និងបរិបទសំរាប់ឱ្យយល់ពីទំនាក់ទំនង និងគំរូ។ ដំណើរការនៃការស្ទង់មើល ឬស្គាល់បាវចនាព្រះគម្ពីរ នាំយើងទៅកាន់គោលលទ្ធិគ្រឹះ និងគោលការណ៍ទាំងឡាយនៃសេចក្ដីសង្គ្រោះ—ទៅកាន់សេចក្ដីពិតដ៏អស់កល្បជានិច្ច ដែលអញ្ជើញព្រះវិញ្ញាណបរិសុទ្ធធ្វើទីបន្ទាល់បញ្ជាក់ (សូមមើល យ៉ូហានទី 1 5:6)។ មធ្យោបាយដើម្បីទទួលទឹករស់ចេញពីអាងព្រះគម្ពីរនេះ គឺជាតំរូវការ និង ម៉ឺងម៉ាត់បំផុត វាក៏នាំទៅរកការស្អាងចិត្ត និងភាពស្រស់ថ្លាខាងវិញ្ញាណដ៏អស្ចារ្យបំផុត។ ហើយបទគម្ពីរ គឺមានពេញទៅដោយបាវចនាដ៏មានអានុភាព។

ឧទាហរណ៍ ព្រះគម្ពីរមរមន លេចចេញមកនៅជំនាន់នេះដើម្បី "ផ្ចាញ់សាសន៍យូដា និងសាសន៍ដទៃថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ជាព្រះដ៏អស់កល្បជានិច្ច ទ្រង់សម្ដែងឱ្យឃើញព្រះអង្គទ្រង់ដល់គ្រប់សាសន៍" (ទំព័រចំណងជើងព្រះគម្ពីរមរមន)។ បាវចនាសំខាន់ និងកើតផ្ទួនៗនៃព្រះគម្ពីរមរមន គឺការអញ្ជើញឱ្យមនុស្សទាំងអស់ "មកឯព្រះគ្រីស្ទ ហើយឱ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ចុះ" (មរ៉ូណៃ10:32)។ ការបង្រៀន ការព្រមាន ការដាស់តឿន និងរឿងទាំងឡាយនៅក្នុងសៀវភៅគម្ពីរអស្ចារ្យនេះផ្ដោតទាំងស្រុង និងធ្វើទីបន្ទាល់អំពីព្រះយេស៊ូវ ជាព្រះគ្រីស្ទ ជាព្រះប្រោសលោះ និងអង្គសង្គ្រោះរបស់យើង។

ខ្ញុំសូមឱ្យផ្ដល់ឧទាហរណ៍បន្ថែមមួយចំនួនទៀតអំពីបាវចនាសំខាន់ក្នុងការប្រើបទគម្ពីរចេញមកពីព្រះគម្ពីរមរមនះ

"បើ . . . កូនចៅមនុស្សកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ នោះទ្រង់នឹងចិញ្ចឹមគេ ហើយផ្ដល់កម្លាំងដល់គេ ព្រមទាំងផ្ដល់ផ្លូវឱ្យ ដើម្បីគេអាចសំរេចនូវអ្វីៗ ដែលទ្រង់បានបញ្ជាពួកគេ" (នីហ្វៃទី 1 17:3)។

"ឈានទៅមុខ ដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ " (នីហ្វៃទី 2 31:20)។

"មានមនុស្សលោក ដើម្បីឱ្យគេអាចមានសេចក្ដីអំណរ" (នីហ្វៃទី 2 2:25)។

"ដោយសារកម្លាំងនៃព្រះអម្ចាស់ នោះលោកនឹងអាចធ្វើបាននូវកិច្ចការគ្រប់យ៉ាង" (អាលម៉ា 20:4)។

"អំពើទុច្ចរិតពុំដែលជាសុភមង្គលឡើយ" (អាលម៉ា 41:10)។

បើអ្នកសន្សាថាមិនសើច នោះខ្ញុំនឹងប្រាប់អ្នកអំពីវិធីសាមញ្ញមួយ ដែលខ្ញុំស្ទង់មើលបាវចនាព្រះគម្ពីរ។ ខ្ញុំមិនលើកទឹកចិត្ត ឬផ្ដល់អនុសាសន៍ឱ្យអ្នកប្រើរបៀបដូចគ្នានេះទេ មនុស្សផ្សេងគ្នាប្រើវិធីសាស្ត្រខុសគ្នាដែលមាន ប្រសិទ្ធភាពដូចគ្នា។ ខ្ញុំពិពណ៌នាដោយសាមញ្ញាអំពីដំណើរដែលវាល្អសំរាប់ខ្ញុំ។

នៅពេលរៀបចំសំរាប់ការឡើងនិយាយនៅពេលថ្មីៗនេះ ខ្ញុំចាប់អារម្មណ៍ថានឹងនិយាយអំពីវិញ្ញាណ និងគោលបំណងនៃការប្រមូលផ្ដុំ។ ខ្ញុំបានសិក្សា និងពិចារណាសារលិខិតសន្និសីទថ្មីៗនេះរបស់អែលឌើររ៉ាស្សែល អែម នែលសុន ស្ដីអំពីគោលការណ៍នៃការប្រមូលផ្ដុំ (សូមមើល Conference Report, Sept.—Oct. 2006, 83–87, ឬ *Ensign* ខែវិច្ឆិកា ឆ្នាំ 2006, 79–82) ហើយប្រធានបទនោះគឺត្រូវយ៉ាងល្អចំពោះលក្ខណៈ និងការរៀបចំសំរាប់ការ ឡើងនិយាយរបស់ខ្ញុំ (សូមមើល *The Spirit and Purposes of Gathering (វិញ្ញាណ និងគោលបំណងនៃការប្រមូលផ្ដុំ* [address deliverd at a BYU—Idaho devotional ខែតុលា ឆ្នាំ 31, 2006])។

ខ្ញុំដឹងថា ខ្ញុំបានរៀនយ៉ាងច្រើនចេញមកពីបទគម្ពីរពីការប្រមូលផ្ដុំ។ ដូច្នេះខ្ញុំដឹងហើយថតចម្លងគ្រប់បទគម្ពីរ នៅក្នុងបទដ្ឋានព្រះគម្ពីរ ដែលមានពាក្យ "ប្រមូល" ទាំងអស់។ បន្ទាប់មកខ្ញុំអានបទគម្ពីរនិមួយៗរកមើល ទំនាក់ទំនង គំរូ និងបាវចនា។ វាសំខាន់ដើម្បីកត់សំគាល់ថា ខ្ញុំមិនបានចាប់ផ្ដើមការអានរបស់ខ្ញុំតាមរឿងដាក់លាក់ដែលខ្ញុំកំពុងរកនោះទេ។ ខ្ញុំអធិស្ឋានសុំជំនួយពីព្រះវិញ្ញាណបរិសុទ្ធ ហើយចាប់ផ្ដើមអានតាមធម្មតា។

នៅពេលខ្ញុំមើលបទគម្ពីរអំពីការប្រមូលផ្ដុំ ខ្ញុំគូសចំណាំខគម្ពីរ ព្រមទាំងកថាខណ្ឌ ឬចំនុចនៃការសង្កត់បញ្ជាក់ដូចគ្នា ដោយខ្មៅដៃពណ៌។ ដល់ពេលខ្ញុំអានបទគម្ពីរ



© 2007 by Intellectual Reserve, Inc។ រក្សាសិទ្ធគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/06។ អនុមតិការបកប្រែៈ 6/06 ។ ការបកប្រែនៃ "A Reservoir of Living Water." 02153 258

ទាំងអស់ហើយ ខគម្ពីរខ្លះគូសចំណាំដោយពណ៌ក្រហម ខ្លះទៀតដោយពណ៌បៃតង ហើយខ្លះទៀតដោយពណ៌ផ្សេងៗ។

ឥឡូវមកដល់ផ្នែកដែលអាចធ្វើឱ្យអ្នកសើចហើយ។ បន្ទាប់មកខ្ញុំយកកន្ត្រៃមកកាត់បទគម្ពីរដែលខ្ញុំថតចម្លងនោះ ហើយដាក់វាតាមពណ៌។ វាបង្កើតជាពំនូកបទគម្ពីរគូសពណ៌ក្រហមធំមួយ ពំនូកពណ៌បៃតងធំមួយ ជាដើម។ រួចហើយខ្ញុំបានរើសបទគម្ពីរពីពំនូកធំនីមួយៗដាក់ចូលក្នុងពំនូកតូច។ កាលពីនៅថ្នាក់ទីមួយខ្ញុំច្បាស់ជាចូលចិត្តកាត់ ក្រដាសជាពំនូកណាស់ហើយមើលទៅ!

លទ្ធផលពីការកាត់នេះបានបង្រៀនខ្ញុំនូវរឿងអស្ចារ្យមួយអំពីគោលការណ៍នៃការប្រមូលផ្តុំ។ ឧទាហរណ៍ ខ្ញុំរៀនពីការពិនិត្យមើលពំនូកធំរបស់ខ្ញុំថា បទគម្ពីរពិពណ៌នាយ៉ាងហោចណាស់ពីគន្លឹះបីផ្នែកនៃការប្រមូលផ្តុំថា៖ *គោលបំណង* នៃការប្រមូលផ្តុំ និង*ប្រភេទ* និង*ទីកន្លែង* នៃការប្រមូលផ្តុំ និង*ពរជ័យ* នៃការប្រមូលផ្តុំ។

ខ្ញុំកត់សំគាល់ឃើញថា គោលបំណងចំបងមួយចំនួនអំពីការប្រមូលផ្តុំ គឺដើម្បីថ្វាយបង្គំ (សូមមើល ម៉ូសាយ 18:25) ដើម្បីទទួលដំបូន្មាន និងការបង្រៀន (សូមមើល ម៉ូសាយ 18:7) ដើម្បីស្ថាបនាសាសនាចក្រ (សូមមើល គ និង ស 101:63-64) និងដើម្បីផ្តល់ការការពារ និងទីជ្រកកោន (សូមមើល គ និងស 115:6)។ នៅក្នុងការសិក្សាអំពី *ប្រភេទ* និង*ទីកន្លែង* នៃការប្រមូលផ្តុំ ខ្ញុំបានរកឃើញថា យើងត្រូវបានប្រមូលផ្តុំនៅក្នុងក្រុមគ្រួសារដ៏អស់កល្បជានិច្ច (សូមមើលម៉ូសាយ 2:5) ចូលក្នុងសាសនាចក្រដែលបានស្តារឡើងវិញ (សូមមើល គ និង ស 101:64–65) ចូលក្នុងស្តេកនៃក្រុងស៊ីយ៉ូន (សូមមើល គ និង ស 109:59) ចូលក្នុងព្រះវិហារបរិសុទ្ធ (សូមមើល អាលម៉ា 26:5–6) និងចូលក្នុងទីតាំងធំពីរគឺ៖ ទីក្រុងយេរូសាឡិមចាស់ (សូមមើលអេធើរ 13:11) និងទីក្រុងស៊ីយ៉ូន ឬយេរូសាឡិមថ្មី (សូមមើល គ និង ស 42:9 មាត្រានៃសេចក្តីជំនឿ 1:10)។ ខ្ញុំមានអំណរគុណដើម្បីរៀនដឹងថាការស្អាងឡើង (សូមមើលអេភេសូ 4:12–13) ការរក្សាទុក (សូមមើល ម៉ូសេ 7:61) និងកម្លាំង (សូមមើល គ និង ស 82:14) គឺជា*ពរជ័យ* មួយចំនួននៃការប្រមូលផ្តុំ។

តាមដំណើរការនេះ ខ្ញុំរឹតតែមានចិត្តអំណរគុណកាន់តែខ្លាំងចំពោះវិញ្ញាណនៃការប្រមូលផ្តុំ ថាជាផ្នែកសំខាន់នៃការស្តារឡើងវិញនៃរបស់គ្រប់យ៉ាងនៅក្នុងជំនាន់នៃកាលពេញកំណត់។ ឥឡូវខ្ញុំមិនចំណាយពេលដើម្បីរ៉ាយរ៉ាប់រឿងផ្សេងទៀតដែលខ្ញុំបានរៀនអំពីការប្រមូលផ្តុំនោះទេ គោលបំណងរបស់ខ្ញុំនៅទីនេះ គឺបង្ហាញពីរបៀបដោយសង្ខេបមួយអំពីការស្ទង់មើលបាវចនាព្រះគម្ពីរ។

## ពរជ័យទាំងឡាយដែលយើងអាចទទួល

ពរជ័យនៃចំណេះដឹង ការយល់ដឹង វិវរណៈ និងការសប្បាយរីករាយខាងវិញ្ញាណ ដែលយើងអាចទទួល នៅពេលយើងអាន សិក្សា និងស្ទង់មើលបទគម្ពីរ គឺជាការអស្ចារ្យ។ "ការទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ" (នីហ្វៃទី 2 31:20) គឺជាការស្អាងឡើង ការរំភើប និងគួរឱ្យរីករាយ។ ព្រះបន្ទូលល្អ "ព្រោះវាចាប់ផ្តើមពង្រីកព្រលឹងរបស់ខ្ញុំ មែនហើយ វាចាប់ផ្តើមបំភ្លឺយោបល់របស់ខ្ញុំ មែនហើយវាចាប់ផ្តើមមានរសជាតិឆ្ងាញ់ចំពោះខ្ញុំ" (អាលម៉ា 32:28) "មើលចុះ ពាក្យទាំងនោះបានកត់ទុកហើយ ហើយអ្នករាល់គ្នាមានពាក្យទាំងនោះ នៅខាងមុខអ្នក ហេតុដូច្នោះចូរស្ទង់មើលចុះ" (នីហ្វៃទី 3 20:11)—ហើយពួកគេ "ជារន្ធទឹកនៅក្នុង [អ្នក ] នោះ ដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច" (យ៉ូហាន 4:14)។

នៅក្នុងការអាន ការសិក្សា និងការស្ទង់មើលផ្ទាល់ខ្លួនរបស់ខ្ញុំរយៈពេលជាច្រើនឆ្នាំមកនេះ ខ្ញុំបានផ្តោតជាច្រើនទៅលើគោលលទ្ធិនៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ។ គ្មានព្រឹត្តការណ៍ ចំណេះដឹង ឬឥទ្ធិពលណា មានឥទ្ធិពលមកលើខ្ញុំ អំឡុងវ័យ 54 ឆ្នាំរបស់ខ្ញុំនៃជីវិតរមែងស្លាប់នេះ ខ្លាំងជាងការអាន ការសិក្សាឱ្យបានជិតដល់ និងការស្ទង់មើលការទំនាក់ទំនង គំរូ និងបាវចនាដដែលៗ ដែលទាក់ទងទៅនឹងគោលលទ្ធិនៃដង្វាយធួននោះទេ។ គោលលទ្ធិចំបង និងជាគោលលទ្ធិសង្គ្រោះនេះយូរៗទៅ បន្តិចម្តងៗបានចុះមកលើព្រលឹងរបស់ខ្ញុំ ដូចជាទឹកសន្សើមចុះពី លើមេឃ បានជះឥទ្ធិពលលើគំនិត ពាក្យសំដី និងកិច្ចការរបស់ខ្ញុំ (សូមមើលម៉ូសាយ 4:30) ហើយជាក់ស្តែងបានក្លាយទៅជា អណ្តូងទឹករស់សំរាប់ខ្ញុំ។

## ទស្សនៈនិមិត្តរបស់លីហៃ

សារៈសំខាន់នៃការអាន ការសិក្សា និងការស្ទង់មើលបទគម្ពីរ ត្រូវបានលេចឡើងនូវធាតុមួយចំនួននៃ ទស្សនៈនិមិត្តរបស់លីហៃអំពីដើមឈើនៃជីវិត។

ឪពុកជាលីហៃ បានឃើញមនុស្សជាច្រើនក្រុមដើរឆ្ពោះទៅមុខតាមផ្លូវតូច និងចង្អៀតចង់ទៅដល់ដើមឈើ ហើយបរិភោគផ្លែវា។ សមាជិកនៃក្រុមនីមួយៗបានចូលដើរលើផ្លូវតាមទ្វារនៃការប្រែចិត្ត និងបុណ្យជ្រមុជដោយទឹក ហើយបានទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ (សូមមើល នីហ្វៃទី 2 31:17—20)។ ដើមឈើនៃជីវិត គឺជាអ្វី ពិសេសនៅក្នុងសុបិន ហើយត្រូវបានចង្អុលបង្ហាញនៅក្នុងនីហ្វៃទី 1 11 ថាជាតំណាងឱ្យព្រះយេស៊ូវគ្រីស្ទ។ ផ្លែនៅលើដើមឈើ គឺជានិមិត្តរូបនៃពរជ័យទាំងឡាយនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ។ ដែលគួរឱ្យចាប់អារម្មណ៍ នោះបាវចនាសំខាន់នៃព្រះគម្ពីរមរមនគឺ ការអញ្ជើញមនុស្សទាំងអស់ឱ្យមករកព្រះគ្រីស្ទ គឺជាផ្នែកសំខាន់នៅក្នុងសុបិន របស់លីហៃ។ គួរឱ្យចាប់អារម្មណ៍ពិសេសទៀត គឺដំបងដែក ដែលនាំទៅរកដើមឈើ (សូមមើល នីហ្វៃទី 1 8:19)។ ដំបងដែកគឺជាព្រះបន្ទូលរបស់ព្រះ។

នៅក្នុងនីហ្វៃទី 1 8 ខ 21—ដល់ 23 យើងរៀនអំពីក្រុមមនុស្សមួយក្រុម ដែលដើរឆ្ពោះទៅ ហើយចាប់ផ្តើមនៅលើផ្លូវ ដែលនាំទៅរកដើមឈើនៃជីវិត។ ទោះជាយ៉ាងណាក៏ដោយ នៅពេលមនុស្សជួបប្រទះ នឹងអ័ព្ទងងឹត ដែលតំណាងឱ្យសេចក្តីល្បួងរបស់អារក្ស (សូមមើលនីហ្វៃទី 1 12:17) ពួកគេបានវង្វេងផ្លូវ ហើយដើរចេញ ហើយវង្វេងបាត់ទៅ។



© 2007 by Intellectual Reserve, Inc។ រក្សាសិទ្ធគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេស៖ 6/06។ អនុមតិការបកប្រែ៖ 6/06 ។ ការបកប្រែនៃ "A Reservoir of Living Water." 02153 258

វាសំខាន់ដើម្បីកត់សំគាល់ថា វាគ្មានបាននិយាយអំពីដំបងដែកនៅក្នុងខទាំងនេះ។ អ្នកទាំងឡាយណាដែលព្រងើយ ឬមិនខ្វល់ពីព្រះបន្ទូលនៃព្រះ នោះមិនអាចប្រើត្រីវិស័យដ៏ទេវភាព ដែលចង្អុលផ្លូវឱ្យទៅរកព្រះអង្គសង្គ្រោះទេ។ ចូរពិចារណាថា ក្រុមនេះដើរនៅលើផ្លូវ ហើយដើរឆ្ពោះទៅមុខ បង្ហាញពីរង្វាស់ជំនឿមួយទៅលើព្រះគ្រីស្ទ និងការផ្លាស់ចិត្តជឿខាងវិញ្ញាណ ប៉ុន្តែពួកគេត្រូវបានបង្វែរដោយសេចក្ដីល្បួងរបស់អារក្ស ហើយត្រូវវង្វេងបាត់។

នៅខ 24 ដល់ 28 នៃជំពូកទី 8 យើងបានអានអំពីមនុស្សក្រុមទីពីរ ដែលនៅលើផ្លូវតូច និងត្រង់ចង្អៀត នាំទៅរកដើមឈើ នៃជីវិត។ ក្រុមនេះបានប្រជ្រៀតពុះពារអព្ភ័ន្តរនៃសេចក្ដីងងឹតទៅមុខ ដោយដើរស្ទួតាមដំបងដែក រហូតដល់ពួកគេទៅដល់ ហើយបរិភោគផ្លែឈើនោះ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលក្រុមមនុស្សទីពីរនេះ ត្រូវបានមនុស្សដែលនៅអគារដ៏ធំ ហើយទូលាយចំអកឱ្យ ពួកគេមានការខ្មាស់អៀនពីព្រោះមានអ្នកចំអកដាក់គេ ហើយពួកគេធ្លាក់ចូលផ្លូវហាមឃាត់ ហើយវង្វេងបាត់អស់ទៅ។ សូមកត់សំគាល់ថា ក្រុមនេះត្រូវបានពិពណ៌នាថា *ដើរស្ទួ* តាមដំបងដែក។

វាជារឿងសំខាន់ដែលក្រុមមនុស្សទីពីរប្រជ្រៀតទៅមុខដោយសេចក្ដីជំនឿ និងការតាំងចិត្ត។ ពួកគេក៏មាន ពរជ័យនៃដំបងដែកបន្ថែម *ហើយពួកគេដើរស្ទួតាមវា!* ទោះយ៉ាងណាក៏ដោយ នៅពេលពួកគេជួបប្រទះនឹងការធ្វើទុក្ខ បុកម្នេញ និងភាពមិនអនុគ្រោះ ពួកគេធ្លាក់ទៅចូលផ្លូវហាមឃាត់ ហើយវង្វេងបាត់។ ទោះជាមានសេចក្ដីជំនឿ ការតាំងចិត្ត និងព្រះបន្ទូលរបស់ព្រះក៏ដោយ ក៏ក្រុមនេះត្រូវវង្វេង—ប្រហែលមកពីពួកគេគ្រាន់តែអាន *ឬ* សិក្សា *ឬ* ស្ទង់មើលបទគម្ពីរម្ដងម្កាល។ ការដើរស្ទួតាមដំបងដែក ផ្ដល់យោបល់ឱ្យខ្ញុំថាវាគ្រាន់តែជាការសិក្សា "ពេលខ្លី" ឬ មិនទៀងទាត់ ជាជាងឱ្យខ្ជាប់ខ្ជួន ជ្រមុជទៅក្នុងព្រះបន្ទូលរបស់ព្រះ។

នៅក្នុងខទី 30 យើងបានអានអំពីមនុស្សក្រុមទីបី ដែលប្រជ្រៀតទៅមុខដោយកាន់ដំបងដែកយ៉ាងខ្ជាប់ជានិច្ច រហូតដល់ពួកគេមកដល់ ហើយដួលចុះ ហើយបរិភោគផ្លែឈើនោះទៅ។ កថាកណ្ឌចំបងនៅក្នុងខនេះ គឺ *កាន់យ៉ាងខ្ជាប់ជានិច្ច* ទៅនឹងដំបងដែក។

ក្រុមទីបីក៏បានប្រជ្រៀតទៅមុខដោយសេចក្ដីជំនឿ និងការផ្លាស់ប្រែចិត្តជឿដែរ ទោះជាយ៉ាងណាក៏ដោយ គ្មានការចង្អុលបង្ហាញណា ដែលថាពួកគេវង្វេង ធ្លាក់ចូលក្នុងផ្លូវហាមឃាត់ ឬវង្វេងបាត់ទៅនោះឡើយ។ ប្រហែលជាមកពីក្រុមទីបីនេះអាន *ខ្ជាប់ខ្ជួន និង* សិក្សា *និង* ស្ទង់មើលបន្ទូលព្រះគ្រីស្ទ។ ប្រហែលជាវាគឺជាលំហូដ៏ខ្ជាប់ខ្ជួននៃទឹករស់ ដែលបានសង្គ្រោះក្រុមទីបីនេះពីការវិនាស។ នេះគឺជាក្រុម ដែលអ្នក និងខ្ញុំ គួរតែព្យាយាមចូលជាមួយ។

"ចុះតើដំបងដែកដែលឪពុកយើងបានឃើញ ដែលនាំទៅឯដើមឈើនោះ មានន័យដូចម្ដេច?

"ហើយខ្ញុំបាននិយាយទៅពួកគេថា នេះគឺជាព្រះបន្ទូលនៃព្រះ ហើយអស់អ្នកណាដែលស្ដាប់តាមព្រះបន្ទូលនៃព្រះ ហើយតោងជាប់តាមព្រះបន្ទូលនៃព្រះ នោះនឹងមិនត្រូវវិនាសឡើយ សូម្បីតែការល្បួងនិងព្រួញភ្លើងរបស់មារសត្រូវ ក៏មិនអាចឈ្នះលើគេ ដល់ធ្វើឱ្យគេខ្វាក់ ដើម្បីនាំគេទៅឯសេចក្ដីបំផ្លិចបំផ្លាញបានឡើយ" នីហ្វៃទី 1 15:23–24 បន្ថែមអក្សរទ្រេត។

តើនោះវាខុសគ្នាយ៉ាងម៉េចរវាងការដើរស្ទួតាម និងការកាន់ដំបងដែកយ៉ាងខ្ជាប់ជានិច្ច? ខ្ញុំសូមឱ្យយោបល់ថា ការកាន់យ៉ាងខ្ជាប់ទៅនឹងដំបងដែកតំរូវឱ្យមានការអធិស្ឋាន ហើយប្រើវិធីទាំងបីនៃការទទួលបានទឹករស់ឱ្យខ្ជាប់ខ្ជួន ដែលយើងបានពិភាក្សានៅរាត្រីនេះ។

"ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំឃើញថាដំបងដែក ដែលឪពុកខ្ញុំបានឃើញមក គឺជាព្រះបន្ទូលនៃព្រះ ដែលនាំទៅឯប្រភពនៃទឹករស់ ឬទៅឯដើមជីវិត ឯទឹកនោះគឺជាតួយ៉ាងនៃសេចក្ដីស្រឡាញ់នៃព្រះ ហើយខ្ញុំក៏បានឃើញថាដើមជីវិតនោះ គឺជាតួយ៉ាងនៃសេចក្ដីស្រឡាញ់នៃព្រះដែរ" (នីហ្វៃទី 1 11:25)។

មធ្យោបាយនីមួយៗទាំងនេះ—ការអានពីដើមដល់ចប់ ការសិក្សាតាមប្រធានបទ និងការស្ទង់មើលសំរាប់រកមើល ការទំនាក់ទំនង គំរូ និងបាវចនា—គឺកំពុងស្ពានឡើង បង្ហាត់ណែនាំ និងផ្ដល់ចំណែកដែលបាត់នៃទឹករស់របស់ ព្រះអង្គសង្គ្រោះ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំជឿថា ការប្រើប្រាស់ដោយទៀងទាត់នូវវិធីសាស្ត្រទាំងបីនោះ វាផលិតបាននូវលំហូរនៃទឹករស់កាន់តែខ្ជាប់ខ្ជួន ហើយមានន័យយ៉ាងធំចំពោះការកាន់តាមដំបងដែកឱ្យជាប់។

តាមរយៈសកម្មភាពធម្មតារាល់ថ្ងៃ អ្នករាល់គ្នា និងខ្ញុំបាត់បង់ធាតុទឹកខ្លះដែលរួមផ្សំយ៉ាងច្រើននៅក្នុងរូបរាង កាយរបស់យើង។ ការស្រេក គឺជាតំរូវការមកពីកោសិកានៃរូបកាយឱ្យរកទឹក ហើយទឹកនៅក្នុងរូបកាយរបស់យើង ត្រូវតែបន្ថែមរៀងរាល់ថ្ងៃ។ វាមិនសមហេតុផលទេដែលថាជួនកាលរាងកាយយើងត្រូវបានចាក់ទឹកបំពេញ បន្ទាប់ពីបានទុកឱ្យខ្សោះជាតិទឹកអស់រយៈពេលជាយូរមកហើយនោះទេ។ ជារឿងពិតដូចគ្នានឹងខាងវិញ្ញាណ។ ការស្រេកខាងវិញ្ញាណគឺត្រូវការទឹករស់។ លំហូរទឹករស់ខ្ជាប់ខ្ជួន គឺជិបយូរៗម្ដង។

តើអ្នករាល់គ្នា ហើយនឹងខ្ញុំអាន សិក្សា និងស្ទង់មើលបទគម្ពីរតាមរបៀបមួយ ដែលជួយយើងឱ្យកាន់ដំបងដែក ឱ្យជាប់ —ឬយើងគ្រាន់តែដើរស្ទួតាមវា? តើអ្នកហើយនឹងខ្ញុំ កំពុងតែខំឆ្ពោះទៅមុខរកប្រភពទឹករស់—ដោយពឹងផ្អែកទៅលើព្រះបន្ទូលនៃព្រះដែរឬទេ? ទាំងនេះគឺជាសំណួរដ៏សំខាន់សំរាប់យើងម្នាក់ៗឱ្យពិចារណាប្រកបដោយ ការអធិស្ឋាន។

នៅពេលយើងបញ្ចប់នៅរាត្រីនេះ យើងនឹងច្រៀងទំនុកដំកើងទាំងអស់គ្នាគឺបទ "The Iron Rod." ប្រាកដណាស់ថា បទចំរៀងនៃពួកសុចរិតនេះ នឹងជាការទូលអង្វរ និងការអធិស្ឋានដ៏អស់ពីចិត្ត (សូមមើល គ និង ស 25:12)។ សូមឱ្យយើងមានត្រចៀកស្ដាប់មេរៀន ដែលទំនុកដំកើងនេះបង្រៀន។

ខ្ញុំសូមធ្វើជាសាក្សីនៃព្រះយេស៊ូវគ្រីស្ទ និងអំពីព្រះចេស្ដានៃព្រះបន្ទូលរបស់ទ្រង់ និងអំពីទ្រង់ជាព្រះបន្ទូល។ ទ្រង់គឺជាព្រះរាជបុត្រានៃព្រះវរបិតាដ៏នៅអស់កល្បជានិច្ច



© 2007 by Intellectual Reserve, Inc។ រក្សាសិទ្ធគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេស៖ 6/06។ អនុមតិការបកប្រែ៖ 6/06 ។ ការបកប្រែនៃ "A Reservoir of Living Water." 02153 258

ហើយខ្ញុំដឹងថា ទ្រង់មានព្រះជន្មរស់។ ខ្ញុំសូមធ្វើបន្ទាល់ថា ការកាន់ឱ្យជាប់ទៅនឹងដំបងដែកនឹងដឹកនាំយើងទៅរកទឹករស់របស់ទ្រង់។ ក្នុងនាមជាអ្នកបំរើទ្រង់ ខ្ញុំសូមអធិស្ឋានសុំឱ្យ ពរជ័យនេះមានមកលើអ្នករាល់គ្នា ដើម្បីឱ្យសេចក្តីប្រាថ្នារបស់អ្នក និងសមត្ថភាពកាន់ដំបងដែកឱ្យជាប់នឹងបានពង្រីកឡើង ដើម្បីឱ្យសេចក្តីជំនឿរបស់អ្នកទៅលើព្រះអង្គសង្គ្រោះរីកចំរើន ហើយលុបបំបាត់សេចក្តីភ័យខ្លាចអ្នកចេញ—និងនៅពេលអ្នកផឹកចូលទៅក្នុងខ្លួនចេញពីអាងព្រះគម្ពីរ អ្នកនឹងមកស្គាល់ទ្រង់។ សូមឱ្យយើងចងចាំជានិច្ចថា

*នៅពេលអំណាចនៃការល្បួងមកដល់*
*ផ្លូវរបស់យើងគ្របដណ្តប់ដោយពពក*
*យើងអាចពឹងលើដំបង*
*ហើយអង្វរសុំជំនួយពីឋានសួគ៌។*
(*ទំនុកដំកើង* លេខ 274)

នៅក្នុងព្រះនាមពិសិដ្ឋនៃព្រះយេស៊ូវគ្រីស្ទ អាមែន។



© 2007 by Intellectual Reserve, Inc។ រក្សាសិទ្ធគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/06។ អនុមតិការបកប្រែៈ 6/06 ។ ការបកប្រែនៃ “A Reservoir of Living Water.” 02153 258